00855458

E239

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
23 / 10 / 2012
ម៉ោង (Time/Heure) : 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង សាធារណៈ / Public

ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១២

ជូនចំពោះ: មេធាវីការពារជនជាប់ចោទ អៀង សារី
សហព្រះរាជអាជ្ញា, សហមេធាវីនាំមុខ
តំណាងដើមបណ្តឹងរដ្ឋប្បវេណី,
សាស្ត្រាចារ្យ A John CAMPBELL,
វេជ្ជបណ្ឌិត LOR Vann Thary

ពី: ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ

កម្មវត្ថុ: ការកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រ (សាស្ត្រាចារ្យ Campbell និង វេជ្ជបណ្ឌិត LOR Vann Thary)

១. បន្ថែមពីលើអនុស្សរណៈ E238 អង្គជំនុំជម្រះសាលាដំបូងតែងតាំងវេជ្ជបណ្ឌិត LOR Vann Thary ដែលជាអ្នកជំនាញវេជ្ជសាស្ត្រដើម្បីពិនិត្យរួមគ្នាជាមួយសាស្ត្រាចារ្យ Campbell ទៅលើជនជាប់ចោទ អៀង សារី និងធ្វើរបាយការណ៍ត្រឡប់មកឱ្យអង្គជំនុំជម្រះវិញ។

២. អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីថាសាស្ត្រាចារ្យ Campbell និងវេជ្ជបណ្ឌិត LOR Vann Thary នឹងពិនិត្យជនជាប់ចោទ អៀង សារី នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ហើយបន្ទាប់មក ពួកគាត់ម្នាក់ ឬទាំងពីរនាក់នឹងផ្តល់សក្ខីកម្មនៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ នេះ នៅចំពោះមុខអង្គជំនុំជម្រះ។